# របាយការណ៍
# ស្តីពី
# សកម្មភាពការងារប្រចាំខែឧសភា ឆ្នាំ២០១០
# របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
# និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុង ខែឧសភា ឆ្នាំ២០១០ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធមិដោយមានអគ្គលេខាធិការដ្ឋាន ជាអង្គភាពប្រតិបត្តិ បានដំណើរការការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម :

## ១.ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-ទទួលរបាយការណ៍ លេខ០០៣ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការបូកសរុបលទ្ធផលនៃការអនុវត្តការងារត្រីមាសទី១ ឆ្នាំ២០១០ និងទិសដៅបន្ត

-ទទួលលិខិតលេខ ២៤៤៨ សហវ.ពវ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីសំណើសុំពិនិត្យ និងផ្តល់យោបល់លើឯកសារ (CPIA 2009) របស់ធនាគាពិភពលោក

-ទទួលលិខិតលេខ៦៩៩ លស ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០ ពីទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើអញ្ជើញ និងចាត់តាំងតំណាងអគ្គលេខាធិការដ្ឋាន ១ រូប ចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពី"ការរៀបចំបង្កើតផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រនៅទីស្តីការគណៈរដ្ឋមន្ត្រី នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ នៅសណ្ឋាគារភ្នំពេញ

-ទទួលលិខិតលេខរបស់អង្គការយូអិនឌីភី (UNDP) ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១០ ស្តីពីការអញ្ជើញចូលរួមកិច្ចប្រជុំ "ជំរើសសម្រាប់មាគ៌ាឆ្ពោះទៅរកយុត្តិធម៌" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ នៅសណ្ឋាគារកាំបូឌីយ៉ាណា

-ទទួលលិខិតលេខ ១៧០ លអជ.រប ពីទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១០ អញ្ជើញចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាដើម្បីពិភាក្សាលើ:១-សេចក្តីព្រាងរបាយការណ៍ជាតិលើកទី៤ និងទី៥ ស្តីពីការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទនៅប្រទេសកម្ពុជា។ ២-សេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ។ ៣-បញ្ហាផ្សេងៗ:សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីរដ្ឋសភាលើកិច្ចព្រមព្រៀងវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងសាធារណរដ្ឋកូរ៉េ និងកិច្ចព្រមព្រៀងវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១០ នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ទទួលលិខិតលេខ ១៣៧ រប.៩២១.១០ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០ ពីសាលាដំបូងរាជធានីភ្នំពេញ ស្តីពីសំណើសុំចាត់តំណាង ១ រូប ដើម្បីចូលរួមក្នុងក្រុមការងារតាក់តែងកម្រងព័ត៌មានសេវាសាធារណៈ (ចង្កោមទី៣ ពាក់ព័ន្ធនិងយុត្តិធម៌ និងអាជ្ញាកណ្តាល)

-ទទួលលិខិតលេខ ១៧៧ លអជ.រប ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ ចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើសេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិអតីតយុទ្ធជន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៩ និង២១ ខែឧសភា ឆ្នាំ២០១០

-ទទួលលិខិត របស់អង្គការយូអិនឌីភី ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០ ស្តីពីការលើកពេលប្រជុំស្តីពីមាគ៌ាឆ្ពោះទៅរកយុត្តិធម៌ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០

-ទទួលលិខិតលេខ៦១៩ កអក/គជនា ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីលទ្ធផលនៃការលើកគម្រោងស្នើសុំហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការជប៉ុន (Japan's ODA) របស់ក្រសួង/ស្ថាប័នរាជរដ្ឋាភិបាល ក្នុងឆ្នាំ២០០៩ ( The Appraisal Results of the Request Survey in 2009 ) សម្រាប់អនុវត្តន៍ក្នុងឆ្នាំ២០១០

-ទទួលលិខិតលេខ ០២១/១០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១០ ពីក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងជំនួយព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា នូវរបាយការណ៍ ស្តីពីការវិវត្តរបស់គម្រោងជំនួយព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ ប្រចាំត្រីមាសទី០១ ឆ្នាំ២០១០

-ទទួលលិខិតលេខ ៨១៦ កយរប/១០ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០ ពីក្រសួងយុត្តិធម៌ សំណើអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ "ពិភាក្សាលើកិច្ចការពាក់ព័ន្ធ នឹងការងារនៃតុលាការគំរូ" ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១០ នៅសាលប្រជុំក្រសួងយុត្តិធម៌

- ទទួលលិខិតលេខ ១៧៩ លអជ.រប ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធស្តូបរូបសំណាកនៅទីរួមខេត្តព្រះវិហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០

-ទទួលលិខិតលេខ ១៨០ លអជ.រប ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ចូលរួមជាកិត្តយស ក្នុងពិធីបញ្ចុះបឋមសិលាសាងសង់អាគារទីបញ្ជារដ្ឋានកងវរៈសេនាតូច កងរថក្រោះ រថពាសដែក និងកងវរៈសេនាតូចកាំភ្លើងធំ នៃកងពលធំអន្តរាគមន៍លេខ៣ និងពិធីបូកសរុបលទ្ធផលការងារនិងទិសដៅបន្ត ក្នុងរដូវវស្សារបស់អង្គភាពពាក់ព័ន្ធប្រចាំទិសប្រាសាទព្រះវិហារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជណាចក្រកម្ពុជា និងលោកជំទាវ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០

-ទទួលលិខិតលេខ ១៨៤ លអជ.របចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ដើម្បីផ្តល់ថវិកាជូនគម្រោងជួសជុលប្រាសាទបាគងលើកទី៣ រវាងអាជ្ញារអប្សរា និងក្រុមហ៊ុន (Holcim) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០

-ទទួលលិខិតលេខ ១៨៨ លអជ.រប ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ ចូលរួមជាកិត្តិយសក្នុងពិធីសច្ចាប្រណិធាន និងបំពាក់កន្សែងជូនយុវកាយវីទ្ធិរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម សុខ អាន ឧបនាយករដ្ឋន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានកាយវីទ្ធិកម្ពុជា និងលោកជំទាវ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ នៅពហុកីឡាដ្ឋានជាតិអូឡាំពិក

-ទទួលលិខិតលេខ ១៩០ លអជ.រប ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ ចូលរួមជាកិត្តិយសក្នុងពិធីចុះហត្ថលេខាលើអនុសារណៈយោគយល់គ្នាស្តីពី "ការផ្តល់ជំនួយឥតសំណង លើគម្រោងវាយតម្លៃផលប៉ះពាល់ឯកសារគតិយុត្ត ជូនក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌" រវាងទីស្តីការគណៈរដ្ឋមន្ត្រី និងធនាគាអភិវឌ្ឍន៍អាស៊ី (ADB) ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១០

- ទទួលលិខិតលេខ ១៩១ លអជ.រប ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ ចូលរួមជាកិត្តិយសក្នុងពិធីចុះក្នុងពិធីចុះហត្ថលេខារវាងទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមហ៊ុន (**Vattanac Capital**) លើគម្រោង (**Vattanac Capital** ) ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០

-ទទួលលិខិតលេខ ៦៧១ ក.អ.ក/គជនា ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០ ពីក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ស្តីពីកិច្ចប្រជុំពិគ្រោះយោបល់កម្រិតនយោបាយ ( Policy Dailogue ) រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលជប៉ុន ស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់អភិវឌ្ឍន៍នាថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០

## ខ. ការងារកំណែទម្រង់

-ប្រជុំក្រុមប្រតិបត្តិគម្រោង និងពិនិត្យរបាយការណ៍វាយតម្លៃបញ្ចប់គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា (A2J) នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១០

-ជួបពិភាក្សាជាមួយអ្នកពាក់ព័ន្ធក្នុងការអនុវត្តគម្រោងសិទ្ធិទទួលបានយុត្តិធម៌ A2J (UNDP, MoI MoJ, CLJR)

-ពិភាក្សាអំពីការរៀបចំសន្និសីទស្តីពី ( ADR ) នៅកម្ពុជា នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០

-ពិភាក្សាវិភាគព័ត៌មានសម្រាប់ការធ្វើបច្ចុប្បន្នកម្ម កម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

-រៀបចំអត្ថបទសម្រាប់ព្រឹត្តប័ត្រព័ត៌មាន លេខ 0៤ ឆ្នាំ២០១០ របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

## គ. ផ្សេងៗ

-ចូលរួមប្រជុំអន្តរក្រសួងផ្សេងៗ និងក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

-បានបញ្ជូនមន្ត្រី ០១រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីធនធានសេនេទិច និងកម្មសិទ្ធិបញ្ញានៅទីក្រុង Alnarp ប្រទេសស៊ុយអែត កាលពីថ្ងៃទី0៣ ដល់ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០

-ចូលរួមប្រជុំប្រចាំឆ្នាំលើកទី៣ នៃកិច្ចសហប្រតិបត្តិការកម្ពុជា-អាមេរិក កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ចូលរួមក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ នាថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១០ នៅវិមានរដ្ឋាភិបាល ( ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)

## ៣_ទិសដៅអនុវត្តក្នុងខែឧសភា

-រៀបចំផែនការ ការងារសម្រាប់ផ្នែកផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន

-បន្តការងារបច្ចុប្បន្នកម្ម កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ បច្ចុប្បន្នកម្ម ២០១០-២០១៣

-បន្តការងាររៀបចំកម្រងសេវាព័ត៌មានទាក់ទងវិស័យយុត្តិធម៌

-ការតាមដានការអនុវត្តគម្រោងតុលាការគំរូ

-ការស្វែងយល់អំពីស្ថានភាពរបស់រដ្ឋបាលនៅតាមតុលាការ ។

*រាជធានីភ្នំពេញ, ថ្ងៃទី១១៤ ខែមិថុនា ឆ្នាំ២០១០*

**បានឃើញ និងឯកភាព** | **អ្នកធ្វើរបាយការណ៍**

**អគ្គលេខាធិការ**

ស៊ុន សិរីវុធ

**ស៊ុយ ម៉ុងលាង**